*CAMBODIAN*

# ការដឹកជញ្ជូនដោយរថយន្តឈ្នួលសំរាប់សិស្សានុសិស្សរៀននៅ សាលាវិទ្យាល័យ Ballard ហើយនិង Franklin

ចាប់ផ្តើមនៅក្នុងខែកញ្ញា ឆ្នាំ 2006 ខាងមុខនេះ, សិស្សានុសិស្សណាដែលរៀននៅសាលាវិទ្យាល័យ Ballard ហើយនិង Franklin ដែលមានសិទ្ធជិះរថយន្តទៅសាលា និងត្រូវប្តូរផ្លាស់ឱ្យជិះរថយន្តឈ្នួលទៅសាលារៀនវិញ។ ពួកគេនិងចូលរួមជាមួយសិស្សានុសិស្សជាច្រើននាក់ទៀតដែលរៀននៅមធ្យមសិក្សា ហើយសិស្សានុសិស្សទាំងអស់នោះក៏ធ្លាប់បានជិះរថយន្តឈ្នួលទៅមកសាលារៀនរួចមកហើយដែរ។

## តើសិស្សានុសិស្សណាខ្លះដែលមានសិទ្ធជិះរថយន្តឈ្នួល?

សិស្សានុសិស្សដែលរៀននៅសាលាវិទ្យាល័យ Ballard ហើយនិង Franklin មានសិទ្ធជិះរថយន្តឈ្នួល បើពួកគេទាំងអស់នោះរស់នៅឆ្ងាយពីសាលារៀនពីរម៉ៃយ៍កន្លះ (2.5 miles)។

បើសិស្សរបស់លោកអ្នកមានកម្មវិធីសិក្សាពិសេស IEP (special education IEP), និងមានផ្តល់ជូននូវយានជំនិះដែលស្របទៅតាមកម្មវិធីពិសេសជាមួយ IEP។ បើសិនណាសិស្សរបស់លោកអ្នកមានគម្រោងការជិះរថយន្តពិសេស (504 accessibility), និងមានផ្តល់ជូនរថយន្តពិសេសតាមគម្រោងការណ៍ពិសេសនោះឯង។

## ហេតុអ្វីការប្តូរផ្លាស់នេះមានរួចទៅហើយ?

នេះគឺជាកម្មវិធីសំរាប់ពិសោធន៏មើលនៃសិស្សានុសិស្សដែលរៀននៅសាលាវិទ្យាល័យ Ballard, ហើយនិង Franklin។ បើសិនណាការប្រើរថយន្តឈ្នួលនេះមានបន្តទៅសាលារៀនវិទ្យាល័យផ្សេងៗទៀតទៅពេលអនាគត, ប្រាក់ចំណាយពីមុនៗនិងត្រូវបានកាត់បន្ថយ, ដោយមានន័យថា: ប្រាក់សន្សំនេះនិងសំរាប់ជួយក្នុងការបង្រៀនបន្ថែមទៀត។

សាលារៀននិងធ្វើការប្តូរផ្លាស់បន្ថែមនៅការកំណត់ពេលវេលានៃពេលម៉ោងបើកទ្វានិងបិតទ្វាររបស់សាលារៀន។ នេះមានន័យថា: សាលារៀន Ballard, ហើយនិង Franklin និងត្រូវចាប់ផ្តើមអនុវត្តនៅឆ្នាំក្រោយ។ សាលារៀនវិទ្យាល័យ Ballard និងត្រូវបើកទ្វានៅម៉ោង 8:20AM នាទីព្រឹក – 2:50PM នាទីល្ងាច។ សាលារៀនវិទ្យាល័យ Franklin និងត្រូវបើកទ្វារនៅម៉ោង 8:00AM ព្រឹក – 2:30PM នាទីល្ងាច។

សិស្សានុសិស្សនិងងាយស្រួលទៅសាលារៀនទាន់ពេលវេលា ឬក៏នៅសាលារៀនឱ្យយូរបន្តិច ដើម្បីមានពេលវេលាចូលរួមក្នុងកិច្ចការឬកម្មវិធីផ្សេងៗទៀត។

សិស្សានុសិស្សនិងមានពេលវេលាទៅមកសាលារៀនតាមការជ្រើសរើសដោយជិះរថយន្តឈ្នួល (Metro bus) បានយ៉ាងងាយស្រួល។

## តើសិស្សរបស់ខ្ញុំត្រូវការជិះរថយន្តឈ្នួលមួយណា?

មុននិងសាលាចាប់ផ្តើមចូលរៀននៅក្នុងរដូវឈើជ្រុះស្លឹកនេះ, យើងនិងធ្វើជូនពត៌មានពិតប្រាកដទៅសិស្សម្នាក់ៗ ដែលមានសិទ្ធជិះរថយន្ត (សិស្សានុសិស្សណាដែលរស់នៅឆ្ងាយពីសាលារៀនពីរម៉ៃយ៍កន្លះ (2.5 miles))។ ពត៌មានពិតប្រាកដនេះមាន: ទីកន្លែងនិងពេលវេលាសំរាប់រងចាំរថយន្ត ដែលនិងបង្ហាញប្រាប់ដល់សិស្សម្នាក់ៗ, ដោយសំអាងទៅលើអាសយ័ដ្ឋានរបស់ពួកគេ។

<u>*CAMBODIAN*</u>

## <u>តើសិស្សរបស់ខ្ញុំនឹងត្រូវបង់តម្លៃជិះរថយន្តឈ្នួលដូចម្តេច?</u>

សិស្សានុសិស្សដែលមានសិទ្ធជិះរថយន្ត ((សិស្សានុសិស្សណាដែលរស់នៅឆ្ងាយពីសាលារៀនពីរម៉ៃយ៉ឹកន្លះ (2.5 miles)) និងត្រូវបានទទួល **<u>សំបុត្រជិះរថយន្តឈ្នួលប្រចាំខែ</u>** ទៅមកសាលារៀន **<u>ដោយមិនបាច់បង់លុយ</u>**)។

មុននិងចាប់ផ្តើមចូលរៀននៅក្នុងរដូវឈើជ្រុះស្លឹកនេះ, យើងនិងផ្ញើសំបុត្រជិះរថយន្តឈ្នួល “scrip” ទៅសិស្សានុសិស្សទាំងអស់ដែលមានសិទ្ធជិះរថយន្ត ((សិស្សានុសិស្សណាដែលរស់នៅឆ្ងាយពីសាលារៀនពីរម៉ៃយ៉ឹកន្លះ (2.5 miles)) ដើម្បីបង់តម្លៃជិះឡានឈ្នួលនៅថ្ងៃចូលរៀនដំបូង។ សិស្សានុសិស្សដែលមានសិទ្ធជិះឡានឈ្នួលទៅសាលា និងត្រូវបានទទួលសំបុត្រជិះឡានឈ្នួលនៅថ្ងៃចូលរៀនដំបូងនោះដែរ។

សំបុត្រជិះរថយន្តឈ្នួលគឺប្រើដោយមិនបាច់បង់លុយ, សំបុត្រជិះរថយន្តឈ្នួលគឺអាចធ្វើដំណើរបានគ្រប់ពេលវេលាតាមរថយន្តឈ្នួល Metro Transit **(សំបុត្រជិះរថយន្តឈ្នួលនេះមិនអាចប្រើក្នុងកម្មវិធីពិសេសៗបានឡើយ)**។

សិស្សានុសិស្សណាដែលមានសំបុត្រជិះរថយន្តឈ្នួល គឺអាចជិះរថយន្តឈ្នួលដូចមានទាំងអស់នេះ Community Transit, Everett Transit, Pierce Transit, និងរថយន្តឈ្នួល Sound Transit’s ST Express ហើយនិងរថភ្លើងឈ្នួល (Sounder commuter rail service) ដែលត្រូវបង់លុយបន្ថែមតែហាសិបសេន (50 cents) ទេ។

## <u>តើខ្ញុំត្រូវទាក់ទងជាមួយនរណាប្រសិនបើខ្ញុំមានសំណួរបន្ថែមទៀត?</u>

បើសិនលោកអ្នកមានសំណួរ, សូមលោកអ្នកទាក់ទងទៅមជ្ឈលក្រុមគ្រួសារទ្វេភាសា ទៅលេខទូរសព្ទ័ (206) 252-7750។

*CAMBODIAN*

# លក្ខខ័ណ្ឌនៃការប្រើ – សំបុត្រជិះរថយន្តឈ្នួល

ក្នុងការប្រើសំបុត្រជិះរថយន្តឈ្នួលនេះ លោកអ្នកត្រូវតែយល់ស្របតួវលក្ខខ័ណ្ឌនៃច្បាប់ដំណើរការរបស់ Metro Transit/Seattle Public School District ដែលមានដូចនៅខាងក្រោមនេះ។

**សំរាប់សន្តិសុខ ហើយនិងងាយស្រួលដល់ចំពោះអ្នកជិះរថយន្តឈ្នួល:**

សូមស្វាគមន៏ដល់លោកអ្នកណាដែលបានបង់លុយគ្រប់គ្រាន់សំរាប់ជិះរថយន្តឈ្នួល។ អ្នកដែលជិះរថយន្តឈ្នួលនេះ គឺត្រូវតែគារពសិទ្ធិដល់អ្នកជិះរថយន្តឈ្នួលដូចគ្នាទៅវិញទៅមក។ រថយន្តឈ្នួលមានលក្ខខ័ណ្ឌនៃច្បាប់ដំណើរការ ដែលក្រុងរដ្ឋអភិបាលបានបង្កើតនៅក្នុងរថយន្តឈ្នួល ហើយនិងបានប្រតិបត្តិដោយរដ្ឋាភិបាល ហើយនិងភ្នាក់ងារខាងរថយន្តឈ្នួល (Local and Metro Transit Police)។

**ទាំងអស់នេះគឺជាតវិយាបទដែលល្មើសនិងច្បាប់នៅក្នុងពេលកំពុងជិះរថយន្តឈ្នួល។ អ្នកណាដែលល្មើសនិងច្បាប់និងត្រូវផន្ទាទោសតាមច្បាប់(ចាប់ខ្លួន), ដាក់ពិន័យ(ផាក) ឬក៏ត្រូវបញ្ឈប់ឱ្យជិះរថយន្តឈ្នួល។**

- បង់ប្រាក់មិនគ្រប់គ្រាន់
- ពិសារគ្រឿងស្រវឹងច្រើនហួសកំរិត
- បើកម៉ាញ៉េស្តាប់ ឬក៏ចាក់កាសែតស្តាប់ដោយមិនប្រើប្រដាប់ស្តាប់ជាប់និងត្រចៀក
- ផ្តេកខ្លួន ឬក៏យកកន្លែងច្រើនជាងដែលខ្លួនត្រូវការ
- រំខានអ្នកបើកបរ ឬក៏អ្នកជិះដទៃទៀត
- ការវ៉ៃគ្នា ឬក៏ប្រើពាក្យប្រមាថ(ពាក្យមិនសមរម្យ)
- ពង្រាយសម្រាម ឬក៏ បង្កើតភាពមិនអនាម័យ
- បំផ្លាញទ្រព្យកម្មសិទ្ធរបស់រថយន្ត
- បាំង(ពាំង)ច្រកដើរក្នុងរថយន្ត
- ការជក់បារីនៅក្នុងរថយន្ត
- កាន់របស់របរដែលឆេះដោយងាយ
- ការខាកស្តោះទឹកមាត់
- តោង ឬក៏យោលនៅលើបង្កាន់ដៃ ឬក៏ចន្ទល់
- ដាក់វត្ថុវែងដែលប៉ះពាល់ដល់អ្នកដទៃ ឬក៏ដាក់វត្ថុវែងដែលចេញទៅក្រៅទ្វារឬក៏បង្អួច

ច្បាប់ដំណើរការនៃការជិះរថយន្តឈ្នួលគឺមាននៅកន្លែងខាងក្រោម:

*County Clerk of the Council offices*
*King County Courthouse Room 402*
*516 Third Avenue*
*Seattle, Washington 98104-2386*

ហើយនិងមានស្ទើគ្រប់កន្លែងនៅក្នុងបណ្តាលយ៍ទូទាំងស្រុក។

**ការរំលោបច្បាប់ និងត្រូវដកហូតសំបុត្រជិះរថយន្តជាបន្ទោះអាសន្ន ឬក៏ដកហូតមិនឱ្យលោកអ្នកវិញឡើយ នេះជាច្បាប់របស់រថយន្ត។**

ខ្ញុំបានមើល(អាន)អំពីលក្ខ័ខណ្ឌ៏នៃការជិះរថយន្តនេះហើយ ហើយខ្ញុំនិងគោរពតាមច្បាប់របស់ពួកគេទាំងអស់។

ការចុះហត្ថលេខារបស់សិស្ស ________________________ ការសរសេរឈ្មោះជាអក្សរធំហើយច្បាស់ ______________________

ថ្ងៃ _________________

Original Copy - School     Second Copy - Student